00864712

E219/3

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 11 / 2012
ម៉ោង (Time/Heure) : 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [illegible]

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូ អុត្តារា**

កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១២

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៣៥ ដែលសុំឲ្យមានចំណាត់ការជាបន្ទាន់ ចំពោះរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង (ឯកសារ E219)

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE

00864713

E219/3


អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលបានដាក់ដោយមេធាវីអន្តរជាតិការពារក្ដី នួន ជា ដោយបានស្នើសុំឱ្យមានចំណាត់ការជាបន្ទាន់ ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេសលោក ហោ ណាំហុង ចំពោះសេចក្ដីអត្ថាធិប្បាយបែបចោទប្រកាន់ ដែលគាត់បានធ្វើចំពោះមុខអ្នកសារព័ត៌មាន[១]។ មេធាវីអន្តរជាតិការពារក្ដី នួន ជា បានដាក់សេចក្ដីបន្ថែមខ្លីដែលភ្ជាប់ជាមួយនឹងសំណើនេះ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២ ហើយសហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើ និង សេចក្ដីបន្ថែមខ្លីរបស់ នួន ជា នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២[២]។ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានចេញសេចក្ដីសម្រេចរបស់ខ្លួនទៅលើបណ្ដឹងសាទុក្ខរបស់មេធាវីអន្តរជាតិការពារក្ដី នួន ជា ដែលជំទាស់ទៅនឹងសេចក្ដីសម្រេចលើកទី១ របស់អង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន ៣៥ ពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយបកស្រាយវិសាលភាពនៃវិធាននេះ[៣]។

## ២. សេចក្ដីអត្ថាធិប្បាយ

២. សេចក្ដីអត្ថាធិប្បាយ នៅក្នុងសារព័ត៌មានជាភាសាអង់គ្លេស និងភាសាខ្មែរមានដូចតទៅ៖

**មតិដ៏ខ្លីរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

វាជារឿងអកុសលណាស់ថា អ្នកដែលបន្តការពារកេរដំណែលរបបខ្មែរក្រហម ខិតខំ

---

[១] សំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន ៣៥ សុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេសលោក ហោ ណាំហុង, ឯកសារលេខ E219, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ("សំណើរបស់ នួន ជា")។

[២] សេចក្ដីបន្ថែមខ្លីរបស់ក្រុមមេធាវីការពារក្ដី នួន ជា ចំពោះសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេសលោក ហោ ណាំហុង, ឯកសារលេខ E219/1, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២ ("សេចក្ដីបន្ថែមខ្លីរបស់ នួន ជា"); ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស លោក ហោ ណាំហុង", ឯកសារលេខ E219/2, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[៣] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់វិធានជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារលេខ E176/2/1/4, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក"); *សូមមើលផងដែរ* សេចក្ដីសម្រេចលើពាក្យសុំឱ្យចាត់វិធានការជាបន្ទាន់អនុលោមតាមវិធាន ៣៥ (ឯកសារលេខ E189), ឯកសារលេខ E189/3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២។

បង្វែរការយកចិត្តទុកដាក់ចេញពីកេរមរតករបស់ខ្មែរក្រហម ក្នុងផលប្រយោជន៍នៃការការពាររបស់គេ ដោយបង្វែរទិសពីការយកចិត្តទុកដាក់លើរឿងរបស់គេ ដោយបង្កហេតុឲ្យមានការយល់ច្រឡំមកលើឥស្សរជនសាធារណៈដូចជារូបខ្ញុំ។ ខ្ញុំចង់និយាយយ៉ាងខ្លីពីប្រវត្តិរបស់ខ្ញុំ ដើម្បីជម្រះឲ្យអស់នូវការខ្វែងគំនិតទាំងនេះ។ របបខ្មែរក្រហម គឺជារឿងសោកនាដកម្មមួយ ដែលនៅតែដក់ជាប់ក្នុងអារម្មណ៍ប្រជាជនកម្ពុជារហូតដល់សព្វថ្ងៃ។ ក្នុងនាមជាអ្នកទោសនៅជំរំអប់រំបឹងត្របែក ដែលនៅទីនោះ ខ្ញុំបានបាត់បង់ប្អូនស្រីពីរនាក់ ព្រមទាំងស្វាមីនិងកូនរបស់គេ និងក្មួយស្រីម្នាក់ ក៏ដូចជាសហសេវិកជាច្រើន ខ្ញុំគ្មានអ្វីក្រៅពីការសោកសៅ និងការរំលែកទុក្ខលំបាករបស់ជនរងគ្រោះ និងក្រុមគ្រួសារគេ។ សូម្បីតែមកដល់សព្វថ្ងៃនេះក្តី ក៏ប្រជាជនកម្ពុជានៅតែបន្តរងទុក្ខដោយសារឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម។ ពួកខ្មែរក្រហមមិនត្រឹមតែបានបំផ្លាញប្រជាជនខ្មែរអស់មួយជំនាន់នោះទេ តែក៏បានបំផ្លិចបំផ្លាញស្ទើរតែទាំងអស់ផងដែរនូវអរិយធម៌ខ្មែរ ដែលមកដល់ពេលនេះយើងកំពុងបន្តស្តារឡើងវិញ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការច្បាប់ មិនមែនជាវេទិកានយោបាយនោះទេ។ ខ្ញុំជឿជាក់ថា ការប៉ុនប៉ងធ្វើនយោបាយភាវូបនីយកម្មតុលាការនេះ ឬការបង្កឲ្យមានការខ្វែងគំនិតគ្នា គឺជាទង្វើមិនសមស្របទេ។

ការសង្ឃឹមដ៏ធំធេងរបស់ខ្ញុំ គឺថានៅថ្ងៃណាមួយនឹងរកឃើញនូវយុត្តិធម៌ និងកេរដំណែលរបស់ខ្មែរក្រហម ដែលនឹងត្រូវបោះចោលទៅក្នុងធុងសំរាមប្រវត្តិសាស្ត្រ ដោយលែងមានអ្នកការពារ ឬការខ្វែងគំនិតគ្នាទៀត[៤]។

## ៣. សារណា

៣. មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា ចោទប្រកាន់ថា សេចក្តីអត្ថាធិប្បាយដែលបានធ្វើឡើងដោយលោក ហោ ណាំហុង រដ្ឋមន្ត្រីការបរទេសកម្ពុជា នៅក្នុងសារព័ត៌មានកម្ពុជា "ត្រូវបានគេយល់ឃើញថា ជាការប៉ុនប៉ងមួយដើម្បីមានឥទ្ធិពលទៅលើអង្គជំនុំជម្រះសាលាដំបូង សាក្សីដែលនឹងផ្តល់សក្ខីកម្មជាបន្តបន្ទាប់ ក្រុមមេធាវីការពារក្តី ព្រមទាំងមហាជនទូទៅ បង្កើតបានជា

[៤] "លោក ហោ ណាំហុង ឆ្លើយតបទៅនឹងការអះអាងពីបឹងត្របែក" ('Hor Namhong Addresses Boeng Trabek Claims'), សារព័ត៌មាន *The Cambodia Daily,* ចេញផ្សាយថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ("លោក ហោ ណាំហុង ឆ្លើយតបទៅនឹងការអះអាង"); "កេរដំណែលខ្មែរក្រហម, ហោ ណាំហុង៖ ការធ្វើនយោបាយភាវូបនីយកម្មតុលាការគឺជាទង្វើមិនសមស្រប", កាសែតកោះសន្តិភាព, ចេញផ្សាយថ្ងៃទី ៤-៥ ខែ សីហា ឆ្នាំ ២០១២; សំណើរបស់ នួន ជា, កថាខណ្ឌ ២។

ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក"[៥]។ មេធាវីការពារក្តីអះអាងថា សេចក្តីថ្លែងការណ៍នេះត្រូវបានចេញដើម្បីឆ្លើយតបទៅនឹងសក្ខីកម្មជាសាធារណៈរបស់សាក្សី រ៉ូ ជាមតុន ហៅ ភី ភួន ដែលបានធ្វើឡើងកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ថា នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ("DK") លោក ហោ ណាំហុង គ្រប់គ្រងជំរំអប់រំបឹងត្របែក[៦]។

៤. នៅក្នុងសេចក្តីបន្ថែមខ្លីរបស់ខ្លួន មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា បានធ្វើការសន្និដ្ឋានថា សេចក្តីថ្លែងការណ៍សារព័ត៌មានចុងក្រោយនេះគឺសំដៅដល់សាក្សី ភី ភួន ដែលក្នុងនោះគាត់បានអះអាងថាបានចោទឆ្លើយដាក់ដោយភាន់ច្រឡំដល់លោក ហោ ណាំហុង ក្នុងពេលផ្តល់សក្ខីកម្ម ថា "វាទំនងថាសាក្សី ភី ភួន បានបដិសេធជាសាធារណៈ*នូវសក្ខីកម្មផ្ទាល់មាត់*នៅក្នុងសំណុំរឿង ០០២ ... *ពីព្រោះតែ*សម្ពាធពីរដ្ឋមន្ត្រីការបរទេស តាមរយៈការចេញផ្សាយសេចក្តីថ្លែងការណ៍"[៧]។ ហេតុនេះ មេធាវីអន្តរជាតិសន្និដ្ឋានថា លោក ហោ ណាំហុង "ពិតជាបាន 'គំរាមកំហែងបំភិតបំភ័យ[...] ឬបើមិនដូច្នេះទេ ជ្រៀតជ្រែក*សាក្សី* [...] ដែល[...] បាន [...] ផ្តល់សក្ខីកម្មនៅចំពោះ [...] អង្គជំនុំជម្រះ"[៨]។ មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងបន្ថែមទៀតថា ផលប៉ះពាល់ពីសេចក្តីអត្ថាធិប្បាយដែលបានធ្វើឡើងដោយលោក ហោ ណាំហុង នោះមានកាន់តែខ្លាំងឡើងដោយសារ តួនាទី "មិនអាចប៉ះពាល់បាន" របស់គាត់ក្នុងនាមជារដ្ឋមន្ត្រីមួយរូបនៃរាជរដ្ឋាភិបាលកម្ពុជា, ទំនាក់ទំនងរបស់គាត់តាមការចោទប្រកាន់ជាមួយនឹងបញ្ហានានាក្នុងសំណុំរឿង ០០២/០១, ការបដិសេធរបស់គាត់មិនព្រមមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានកោះហៅ និងប្រវត្តិតាមការចោទប្រកាន់ទាក់ទងនឹង "ការប៉ុនប៉ងដោយកំរោល ដើម្បីបំបិទមាត់អ្នកណាដែលបាននិយាយជាសាធារណៈទាក់ទងនឹងអតីតកាលរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[៩]។

៥. ហេតុនេះ មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះទទួលស្គាល់ថា សេចក្តីអត្ថាធិប្បាយរបស់លោក ហោ ណាំហុង គឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់

[៥] សំណើរបស់ នួន ជា, កថាខណ្ឌ ១។

[៦] សំណើរបស់ នួន ជា, កថាខណ្ឌ ៣ (*ដោយដកស្រង់ពី* សេចក្តីព្រាងប្រតិចារឹកនៃសវនាការ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២, ទំព័រ ៦៣ (ភាសាអង់គ្លេស)។

[៧] សេចក្តីបន្ថែមខ្លីរបស់ នួន ជា, កថាខណ្ឌ ៤ (គូសបញ្ជាក់បន្ថែមក្នុងសំណៅដើម)។

[៨] សេចក្តីបន្ថែមខ្លីរបស់ នួន ជា, កថាខណ្ឌ ៤។

[៩] សំណើរបស់ នួន ជា, កថាខណ្ឌ ១៣-១៤។

អង្គជំនុំជម្រះនៅ អ.វ.ត.ក, ស្នើឱ្យចេញការស្តីបន្ទោសជាសាធារណៈមួយ ព្រមានគាត់មិនឱ្យបញ្ចេញមតិបន្ថែមទៀតដែលមានលក្ខណៈស្រដៀងគ្នា និង "ធ្វើការស៊ើបអង្កេតបន្ថែមដើម្បីស្វែងរកថា តើមានមូលហេតុគ្រប់គ្រាន់" សម្រាប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ដែរឬយ៉ាងណា[១០]។

៦. ក្នុងការឆ្លើយតបវិញ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណូមពរក្នុងសំណើ និងសេចក្តីបន្ថែមខ្លីរបស់មេធាវីការពារក្តី នួន ជា ដោយសំអាងលើមូលដ្ឋានថា មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា ខកខានមិនបានបង្ហាញភស្តុតាងចំពោះអំណះអំណាងពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥។ គោលបំណងនៃវិធាននេះគឺដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះមិនត្រូវបានរារាំង ហើយថា មុខងារយុត្តិធម៌ជាមូលដ្ឋានរបស់អង្គជំនុំជម្រះត្រូវបានការពារ។ ដើម្បីបញ្ចៀសការបំពានដល់វិធាននេះ ដើម្បីធានាថាវិធាននេះផ្តោតទៅលើបញ្ហានានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដើម្បីការពារសេរីភាពក្នុងការបញ្ចេញមតិ ដែលជាលក្ខខណ្ឌកំណត់អប្បបរមាសម្រាប់ធ្វើការស៊ើបអង្កេតគឺជា "ជំនឿមានហេតុផល" មួយដែលត្រូវធ្វើ នៅពេលដែលអាចកើតមានការគំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ ផ្ទុយទៅវិញ នៅពេលដែលវិធានការបន្ទាន់ពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់បុគ្គលណាម្នាក់ ដូចដែលបានដោះស្រាយក្នុងករណីនេះនោះ គេត្រូវបង្ហាញថា បទល្មើសសកម្ម ឬអកម្មដែលសំដៅដល់ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនោះ ត្រូវបានធ្វើឡើងដោយចេតនាពិតប្រាកដ[១១]។

៧. សហព្រះរាជអាជ្ញាបានលើកឡើងថា ការពិនិត្យទៅលើសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយលោក ហោ ណាំហុង ពុំមានមូលដ្ឋានបង្ហាញពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬពុំមានជំនឿមានហេតុផលថា ប្រការនេះអាចកើតឡើងនោះទេ។ អត្ថបទនៃសេចក្តីថ្លែងការណ៍នោះពុំមានការគំរាមកំហែង បំភិតបំភ័យ ហើយថែមទាំងអះអាងបញ្ជាក់ថា អ.វ.ត.ក "គឺជាតុលាការច្បាប់ មិនមែនជាវេទិកានយោបាយនោះទេ"[១២]។ ខុសពីសេចក្តីថ្លែងការណ៍ដែលស្ថិតក្រោមការសម្រេចសេចក្តីពីមុនតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺថា សេចក្តីថ្លែងការណ៍

---

[១០] សំណើរបស់ នួន ជា, កថាខណ្ឌ ២៣; សេចក្តីបន្ថែមខ្លីរបស់ នួន ជា, កថាខណ្ឌ ៧។

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧-៩។

[១២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣។

ដែលត្រូវបានចោទប្រកាន់ធ្វើឡើងដោយលោក ហោ ណាំហុង មិនបានយោងទៅដល់ជនជាប់ចោទណាម្នាក់ទេ និងក៏ពុំបានបញ្ចេញមតិលើពិរុទ្ធភាពរបស់បុគ្គលណាម្នាក់ ចំពោះបទឧក្រិដ្ឋណាមួយដែរ។ សេចក្តីអត្ថាធិប្បាយនោះក៏មិនបាននិយាយយោងទៅដល់ "បញ្ហានានាទាក់ទងអង្គហេតុដែលជា *បញ្ហាដែលកំពុងតែស្ថិតនៅក្នុងការពិនិត្យរបស់តុលាការ (sub judice)*"[១៣]។ ការកំណត់ជាបទចោទនូវសេចក្តីថ្លែងការណ៍នេះគឺជា "ការខំព្យាយាមដោយត្រង់ៗឥតលាក់លៀម និងដែលមិនអាចអនុគ្រោះឱ្យបាន ក្នុងការបញ្ចុះបញ្ចូលចៅក្រមនានានៃអង្គជំនុំជម្រះសាលាដំបូង អំពីការសម្រេចទាក់ទងនឹងការកំណត់អង្គហេតុនៃសេចក្តីអត្ថាធិប្បាយដែលធ្វើឡើងក្រៅច្បាប់របស់លោក ហោ ណាំហុង" ពុំមានមូលដ្ឋានគាំទ្រដោយអត្ថបទនៃសេចក្តីថ្លែងការណ៍នេះ ឬតាមវិធីណាផ្សេងឡើយ ហើយមេធាវីអន្តរជាតិការពារក្តី នួន ជា ក៏មិនបានបង្ហាញថា សេចក្តីថ្លែងការណ៍នេះ "ពិតជាមានផលប៉ះពាល់ ទោះបីមិនមានបំណងជាក់លាក់ក៏ដោយ" ដើម្បីបង្អាក់ដល់ការព្យាយាមរបស់មេធាវីការពារក្តី នួន ជា ក្នុងការបន្តធ្វើការសួរដេញដោលមួយចំនួនពាក់ព័ន្ធនឹងលោក ហោ ណាំហុង៖ ជាសារណាដែលពុំមានសំអាងហេតុគ្រប់គ្រាន់នៅក្នុងកំណត់ហេតុសវនាការ[១៤]។ ហេតុនេះ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះបដិសេធសំណើ និងសេចក្តីបន្ថែមខ្លីរបស់ នួន ជា ទាំងមូល។

## ៤. ច្បាប់ជាធរមាន

៨. នាពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញដល់ភាគីថា មានទង្វើពីរប្រភេទដែលត្រូវបានបញ្ចូលទៅក្នុងសញ្ញាណនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[១៥]។ ប្រភេទទី១ រួមមានបទល្មើសព្រហ្មទណ្ឌដែលត្រូវទទួលទណ្ឌកម្មនានាយោងតាមក្រមព្រហ្មទណ្ឌកម្ពុជា។ សម្រាប់បទល្មើសប្រភេទនេះ ក្រមព្រហ្មទណ្ឌកម្ពុជាកំពុងគ្រប់គ្រងទៅលើបញ្ហានានាដូចជា ទម្រង់នៃការទទួលខុសត្រូវ និងធាតុផ្សំបទល្មើស[១៦]។

---

[១៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៤-១៦។

[១៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៧-១៨ (ដោយបានកត់សម្គាល់បន្ថែមថា មេធាវីការពារក្តី នួន ជា "ខំប្រឹងដាក់បញ្ចូលក្នុងសំណើសុំកាលពីមុនរបស់ខ្លួន ដែលការខំព្យាយាមរបស់ខ្លួនបានបរាជ័យក្នុងការបង្ខំឱ្យលោក ហោ ណាំហុង មកផ្តល់សក្ខីកម្ម" និងបានយោងទៅដល់ផ្នែកនានានៃប្រតិចារឹកសវនាការ ដែលមេធាវីការពារក្តី នួន ជា បានសួរសាក្សីពាក់ព័ន្ធនឹងតួនាទីរបស់លោក ហោ ណាំហុង (អត្ថបទដកស្រង់ត្រូវបានលុបចោល))។

[១៥] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់វិធានការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារលេខ E176/2/1/4, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ (សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក"), កថាខណ្ឌ ៣២-៣៣។

[១៦] សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក, កថាខណ្ឌ ៣២។

00864719

E219/3

៩. ប្រភេទទី២ រួមមានសកម្មភាពតាមបែបរដ្ឋបាល ដែលធ្វើឱ្យអន្តរាយដល់ធម្មានុរូបភាពរបស់តុលាការ និងដែលទាក់ទិននឹងការប្រព្រឹត្តដែលតុលាការអន្តរជាតិដទៃទៀតបានប្រកាសយកមកអនុវត្តជាផ្លូវការ[១៧]។ ចំពោះប្រការនេះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា "លក្ខខណ្ឌធាតុផ្សំអត្តនោម័តជាក់លាក់តាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចំពោះការប្រមាថតុលាការដែលជាបទព្រហ្មទណ្ឌ មានលក្ខណៈតឹងរ៉ឹងខ្លាំងពេកសម្រាប់បទល្មើសផ្នែករដ្ឋបាល។ ជាការគ្រប់គ្រាន់ហើយក្នុងការបង្ហាញថា ការប្រព្រឹត្តដែលជាការរំលោភបំពាន ត្រូវបានធ្វើដោយមានចេតនា មិនមែនដោយចៃដន្យទេ"[១៨]។ វិធានការឆ្លើយតបតាមផ្លូវតុលាការចំពោះបទមិនមែនព្រហ្មទណ្ឌត្រូវតែជាការចាំបាច់ និងមានសមាមាត្រទៅនឹងការប្រព្រឹត្តនោះ និងអាចរួមមានជា "ការព្រមានស្តីបន្ទោស ការជូនដំណឹងដល់អង្គភាពដាក់វិន័យ [...] ការបោះពុម្ពផ្សាយលទ្ធផលនៃដំណើរការនីតិវិធីនៅក្នុងសាព័ត៌មាន ឬការដាកពិន័យរដ្ឋបាលដោយមានកម្រិត"[១៩]។

១០. បើតាមពាក្យពេចន៍នៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង អ.វ.ត.ក អាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើជនណាម្នាក់ជ្រៀតជ្រែក "ដោយចេតនាពិតប្រាកដ" ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[២០]។ អង្គជំនុំជម្រះពិចារណាឃើញថា ពាក្យពេចន៍នៃវិធាននេះគឺតម្រូវឱ្យមាការប្រព្រឹត្តដោយចេតនា ពាក់ព័ន្ធនឹងការប្រព្រឹត្តទាំងអស់ដែលអាចអនុវត្តទណ្ឌកម្មបាន រួមទាំងការប្រព្រឹត្តដែលមានរៀបរាប់នៅក្នុងបញ្ជីនៃអំពើនានាដែលត្រូវបានហាមឃាត់ដោយវិធាន ៣៥(១)។ វិធាន ៣៥(២) នៃវិធានផ្ទៃក្នុងបានបង្កើតជាបទដ្ឋាននៃជំនឿមានហេតុផលដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការចាប់ផ្តើមចាត់វិធានការតាមនីតិវិធីដែលអង្គជំនុំជម្រះអាចយកមកអនុវត្តបាន នៅពេលប្រឈមមុខនឹងការចោទប្រកាន់ពីបទជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល

---

[១៧] សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨-៣៩ (អត្ថបទដកស្រង់ត្រូវបានលុបចោល)។

[១៨] សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨ (អត្ថបទដកស្រង់ត្រូវបានលុបចោល)។

[១៩] សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក, កថាខណ្ឌ ៤៤។

[២០] ពាក្យពេចន៍ជាក់លាក់របស់វិធាន ៣៥(១) នៃវិធានផ្ទៃក្នុងគឺថា៖ "អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" មុនពេលពិចារណាចំពោះអំពើជាច្រើនមិនចេះអស់ ដែលត្រូវបានហាមឃាត់ដោយអនុវិធាននេះ; *សូមមើលផងដែរ* សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៧ ("តាមវិធាន ៣៥(១) ទង្វើនោះត្រូវតែមានចេតនាពិតប្រាកដ" (*ប្រៀបធៀប* សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨))។

របស់អង្គជំនុំជម្រះ[២១]។

## ៥. សំអាងហេតុ

១១. មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា អះអាងថា សេចក្តីអត្ថាធិប្បាយរបស់លោក ហោ ណាំហុង នៅតាមបណ្តាញសារព័ត៌មាននៅកម្ពុជា ផ្តល់មូលហេតុអាចឱ្យជឿបានថា លោក ហោ ណាំហុង បានប៉ុនប៉ងផ្តល់ឥទ្ធិពលពុំត្រឹមត្រូវមកលើអង្គជំនុំជម្រះសាលាដំបូង, សាក្សី, មេធាវីការពារក្តី និងសាធារណជនទូទៅ[២២]។ សម្រាប់ដំណោះស្រាយចំពោះការរំលោភដែលត្រូវបានចោទប្រកាន់ទាំងនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស្តីបន្ទោសលោក ហោ ណាំហុង ជាសាធារណៈ និង ព្រមានលោក ហោ ណាំហុង ជាផ្លូវការមិនឱ្យគាត់ធ្វើសេចក្តីអត្ថាធិប្បាយណាមួយ ដែលមានលក្ខណៈស្រដៀងនេះតទៅទៀត[២៣]។ សេចក្តីបន្ថែមខ្លីរបស់ នួន ជា ក៏បានស្នើសុំឱ្យអង្គជំនុំជម្រះបំពេញកិច្ចស៊ើបសួរ "ដើម្បីបញ្ជាក់ថាតើមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីផ្តួចផ្តើមកិច្ចដំណើរការនីតិវិធី" ប្រឆាំងនឹងលោក ហោ ណាំហុង ដែរឬយ៉ាងណា ដោយបានលើកឡើងថា ពួកគាត់យល់ឃើញថា ការបំភិតបំភ័យដែលត្រូវបានចោទប្រកាន់ ថាបានធ្វើទៅលើសាក្សីឈ្មោះ ភី ភួន គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង[២៤]។

១២. ពាក់ព័ន្ធនឹងការចោទប្រកាន់ថា លោក ហោ ណាំហុង បានព្យាយាមដាក់ឥទ្ធិពលលើសាក្សីម្នាក់ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ៥៤៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចាត់ជាបទល្មើសនូវការផ្សព្វផ្សាយសេចក្តីអត្ថាធិប្បាយ ដែលមានបំណងដាក់ឥទ្ធិលពលលើចម្លើយរបស់សាក្សី។ ដើម្បីបង្កើតការទទួលខុសត្រូវលើទង្វើនេះ ត្រូវតែមានភស្តុតាងបញ្ជាក់អំពីចេតនាក្នុងការដាក់ឥទ្ធិពល បំភិតបំភ័យ ឬជ្រៀតជ្រែករំខានសាក្សី[២៥]។ យ៉ាងណាក៏ដោយអង្គជំនុំជម្រះយល់ឃើញថា សេចក្តីអត្ថាធិប្បាយនេះ ពុំគាំទ្រដល់ទស្សនៈដែលថាអ្នកនិយាយមានចេតនាបែបនេះឡើយ។

---

[២១] វិធាន ៣៥(២) នៃវិធានផ្ទៃក្នុងផ្តល់អំណាចឱ្យអង្គជំនុំជម្រះអាចដោះស្រាយបញ្ហាណាមួយជាបន្ទាន់បាន រៀបចំការស៊ើបអង្កេតដើម្បីស្វែងរកថា តើមានមូលដ្ឋានគ្រប់គ្រាន់ឬទេសម្រាប់ចាប់ផ្តើមកិច្ចដំណើរការនីតិវិធី ឬបញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ។

[២២] សំណើរបស់ នួន ជា, កថាខណ្ឌ ១។

[២៣] សំណើរបស់ នួន ជា, កថាខណ្ឌ ២២-២៣។

[២៤] សេចក្តីបន្ថែមខ្លីរបស់ នួន ជា, កថាខណ្ឌ ៧។

[២៥] *សូមប្រៀបធៀប* សេចក្តីសម្រេចរបស់ អ.ជ.ត.ក ដោយអនុលោមតាមវិធាន ៣៥ វិធានផ្ទៃក្នុង, កថាខណ្ឌ ៤៧។

១៣. សេចក្តីអត្ថាធិប្បាយនេះ គឺធ្វើសំដៅទៅដល់ "មនុស្សទាំងឡាយណាដែលបន្តការពារកេរដំណែល នៃរបបខ្មែរក្រហម" និងពុំមែនសំដៅទៅដល់បុគ្គលដែលមានឈ្មោះជាក់លាក់ ឬការប្រព្រឹត្តណាមួយឡើយ។ គេពុំអាចប្រៀបប្រដូចការថ្កោលទោសអំពី "កេរដំណែលនៃរបបខ្មែរក្រហម" ដែលមានលក្ខណៈទូទៅទាំងក្នុងប្រទេស និងទាំងនៅលើឆាកអន្តរជាតិ ជាមួយសេចក្តីអត្ថាធិប្បាយស្តីពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធនៃសមាជិកជាក់លាក់នៃមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យចំពោះឧក្រិដ្ឋកម្មជាក់លាក់ណាមួយឡើយ។ ជាងនេះទៀត អ្នកធ្វើសេចក្តី អត្ថាធិប្បាយទាំងនេះគូសបញ្ជាក់ថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការ ដែលច្បាប់បានបង្កើតឡើង ពុំមែនជាវេទិកានយោបាយឡើយ ហើយខ្ញុំជឿថា ការប៉ុនប៉ងធ្វើនយោបាយភាវូបនីយកម្មតុលាការ ឬបង្កឱ្យមានភាពចម្រូងចម្រាស់ គឺជារឿងពុំសមស្របឡើយ"។ តាមរយៈនេះ អ្នកធ្វើសេចក្តីអត្ថាធិប្បាយហាក់បីដូចជាយល់អំពីភាពចាំបាច់នៃការងាររបស់ អ.វ.ត.ក ដើម្បីបោះជំហានដោយពុំមានការជ្រៀតជ្រែកខាងនយោបាយ។

១៤. កាលៈទេសៈដែលសាក្សីឈ្មោះ ភី ភួន ត្រូវបានចោទប្រកាន់ថាបានកែប្រែចម្លើយក្នុងសវនាការរបស់គាត់ពាក់ព័ន្ធនឹងលោក ហោ ណាំហុង ពុំគាំទ្រដល់ការសន្និដ្ឋានណាមួយដែលថា លោក ហោ ណាំហុង អាចបានព្យាយាមដាក់ឥទ្ធិពលលើសាក្សីរូបនេះឡើយ ទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ បន្ទាប់ពីមានការផ្សព្វផ្សាយអំពីសេចក្តីអត្ថាធិប្បាយ មានរបាយការណ៍ថា សាក្សីឈ្មោះ ភី ភួន បានថ្លែងតាមរយៈគេហទំព័រជាភាសាខ្មែរមួយថា គាត់បានកែប្រែចម្លើយរបស់គាត់ទាក់ទងនឹងលោក ហោ ណាំហុង ដោយសំអាងថា គាត់មានការភាន់ច្រឡំនៅតុលាការ ដោយសារមានចំនួនដ៏ច្រើនដែលត្រូវបានចោទសួរដោយមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ។ សាក្សីរូបនេះក៏បានបញ្ជាក់ផងដែរថា គាត់មិនដែលបាននិយាយថា លោក ហោ ណាំហុង ជាអ្នកទទួលគុកបឹងត្របែកនោះទេ ហើយក៏មិនដែលបានប្រើពាក្យថា "គុក" នៅក្នុងពេលផ្តល់សក្ខីកម្មដែរ[26]។ មានការដកស្រង់សម្តីរបស់សាក្សីដែលបាននិយាយថា "ខ្ញុំត្រូវបានចោទសួរសំនួរដូចៗគ្នាម្តងហើយម្តងទៀត ក្នុងរយៈពេលយូរ។ ខ្ញុំឈឺ ហើយមានការភាន់ច្រឡំជាមួយនឹងសំនួរ"។ គាត់បានបញ្ជាក់ផង

---

២៦ Chhorn Chansy និង Julia Wallace, "សាក្សីនៅតុលាការខ្មែរក្រហមកែប្រែចម្លើយពាក់ព័ន្ធនឹងលោក ហោ ណាំហុង" សារព័ត៌មាន *The Cambodia Daily*, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ("សាក្សីនៅតុលាការខ្មែរក្រហមកែប្រែចម្លើយ"), ទំព័រ ១៧។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៦១-៦១ (ជាភាសាអង់គ្លេស) (ដែលបង្ហាញអំពីការសួរសំណួរជាច្រើនទៅសាក្សី រួមទាំងមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងតួនាទីដែលត្រូវបានចោទប្រកាន់របស់លោក ហោ ណាំហុង)។

ដែរថា គាត់មិនបានដឹងអ្វីច្រើនទេអំពីតួនាទីរបស់ លោក ហោ ណាំហុង នៅពេលនោះ[27]។ សារព័ត៌មាន ដដែលបានបានគូសបញ្ជាក់ថាសាក្សីក៏បានបញ្ជាក់ថា គ្មានអ្នកណាបានដាក់សម្ពាធ គំរាមកំហែង ឬស្នើសុំឱ្យគាត់ផ្តល់ចម្លើយពាក់ព័ន្ធនឹងលោក ហោ ណាំហុង ឡើយ[28]។

១៥. ជាងនេះទៀត ហើយកាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ នៃ អ.វ.ត.ក ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន ដើម្បីគាំពារសុខមាលភាពរបស់បុគ្គលទាំងអស់ ដែលផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក បានចុះជួបសាក្សីឈ្មោះ ភី ភួន ដើម្បីបញ្ជាក់អំពីកាលៈទេសៈដែលគាត់ កែប្រែចម្លើយរបស់គាត់តាមបណ្តាញសារព័ត៌មាន។ កាលពីពេលនោះ ឬនៅពេលក្រោយមកទៀត អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពុំបានរាយការណ៍អំពីការព្រួយបារម្ភណាមួយមកអង្គជំនុំជម្រះឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងបានផ្ទៀងផ្ទាត់បន្ថែមទៀតជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ មុនពេលចេញសេចក្តីសម្រេចនេះថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពុំមានហេតុផលអាចឱ្យជឿបានថា សាក្សីបានកែប្រែចម្លើយរបស់គាត់ ដោយសារមានសម្ពាធ ឬការជ្រៀតជ្រែកពុំសមស្របឡើយ។

១៦. ជាចុងក្រោយ អង្គជំនុំជម្រះចាត់ទុកថាការចោទប្រកាន់របស់មេធាវីការពារក្តី នួន ជា ដែលនៅសេសសល់ ពាក់ព័ន្ធនឹងផលប៉ះពាល់តាមការសន្មតនៃសេចក្តីអត្ថាធិប្បាយដែលត្រូវបានចោទប្រកាន់លើលោក ហោ ណាំហុង ដែលកើតចេញពីតួនាទីរបស់គាត់នៅកម្ពុជា គឺជាការប៉ាន់ស្មានទាំងស្រុង។ លើសពីនេះ ការខកខានរបស់លោក ហោ ណាំហុង ក្នុងការឆ្លើយតបទៅនឹងដីកាកោះអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេត គឺជាបញ្ហាមួយដែលអង្គបុរេជំនុំជម្រះបានសម្រេចរួច

---

[២៧] អត្ថបទកាសែត ខេមបូឌា ដេលី ទំព័រ ១៧។ សូមមើលផងដែរ ប្រតិចារឹកសវនាការ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៥០ ដល់ ៥៨។ សាក្សីបានឆ្លើយទៅនឹងសំនួររបស់សហព្រះរាជអាជ្ញា ដូចខាងក្រោមនេះ៖ សំនួរ: តើមានពេលណាមួយ បឹងត្របែក ត្រូវបានផ្ទេរពីមន្ទីរ ៨៧០ ទៅស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ដែរ ឬទេ? ចម្លើយ: នៅចុងឆ្នាំ ១៩៧៨ ប៉ង់ បានបាត់ខ្លួន ហើយបន្ទាប់មក វ៉ន បានមកគ្រប់គ្រងមន្ទីរនេះ។ បន្ទាប់មក មន្ទីរ ៨៧០ បានបញ្ជាមកថា មន្ទីរបឹងត្របែក ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ខ ១។ នៅពេលនោះ បញ្ញវ័ន្តឈ្មោះ សេង ហុង គឺជាប្រធាន ហើយគាត់នៅទីនោះផង ដែរ ហើយលោក ហោ ណាំហុង ក៏នៅទីនោះដែរ (ប្រតិចារឹក ៣០ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៥២)។ នៅពេលសួរដោយមេធាវីអ៊ីយ៉ានូហ្ស៊ី ដែលជាមេធាវីអន្តរជាតិការពារក្តី នួន ជា នោះ សាក្សីបានឆ្លើយដូចតទៅ៖ សំនួរ: តើដែលមានប្រធាន ឬអនុប្រធាននៃមន្ទីរបឹងត្របែកដែរ ទេ ដែលជាលោក ហោ ណាំហុង? ចម្លើយ: នៅពេលដែលតំណាងរបស់ក្រសួងការបរទេសទៅទទួលគាត់ គឺគាត់ជាប្រធានមន្ទីរបឹងត្របែក (ប្រតិចារឹកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៦១ ដល់ ៦៣)។

[២៨] សាក្សីនៅតុលាការខ្មែរក្រហមកែប្រែចម្លើយ, ទំព័រ ១៧។

ហើយ និងពុំចាំបាច់មានការពិនិត្យមើលឡើងវិញម្តងទៀតឡើយ[29]។ ជាងនេះទៀត និងដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់ សំណើរបស់ភាគីស្នើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅសវនាការលើសំណុំរឿង ០០២/០១ នៅស្ថិតក្រោមការពិចារណា[30]។

១៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ភាសានៃសេចក្តីអត្ថាធិប្បាយ ឬកាលៈទេសៈទាំងឡាយជុំវិញសេចក្តីអត្ថាធិប្បាយរបស់សាក្សីឈ្មោះ ភី ភួន ពុំគាំទ្រដោយផ្ទាល់ ឬដោយប្រយោលនូវចេតនាណាមួយរបស់លោក ហោ ណាំហុង ក្នុងការជ្រៀតជ្រែករំខានសាក្សីនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ឡើយ ហើយក៏វាពុំផ្តល់មូលដ្ឋានសមហេតុផលណាមួយដើម្បីអាចឱ្យជឿបានថា ការជ្រៀតជ្រែកនេះអាចបានកើតឡើង សមល្មមដើម្បីឱ្យអង្គជំនុំជម្រះអនុវត្តសិទ្ធិអំណាចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុងឡើយ។

---

[២៩] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ឯកសារ D314/1/12, ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១២, *សូមមើលផងដែរ* វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ("លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ")។

[៣០] សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ (ឯកសារលេខ E189), ឯកសារ E189/3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២, កថាខណ្ឌ ១១ (ដែលបានកត់សម្គាល់ឃើញថា ទាក់ទងនឹងសាក្សីដែលមេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅដើម្បីស្តាប់សក្ខីកម្មថាក្នុងការអនុវត្តអន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីសម្រេចថាតើអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មបុគ្គលណាខ្លះ ក្នុងចំណោមបុគ្គលចំនួន ១០៥៤ រូប ដែលភាគីទាំងអស់បានស្នើសុំស្តាប់ចម្លើយនៅសវនាការ អង្គជំនុំជម្រះបានផ្តល់ឱកាសទៅក្រុមមេធាវីការពារក្តីទាំងអស់ ដើម្បីបញ្ជាក់ថាតើសាក្សី ណាខ្លះជាសាក្សីសំខាន់ ដើម្បីបដិសេធការចោទប្រកាន់ទៅលើជនជាប់ចោទ។ *សូមមើលឧទាហរណ៍* ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, ឯកសារ E218, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២, កថាខណ្ឌ ១២ និងបុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ឯកសារ E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ (ដែលមានរាយនាមបុគ្គលទាំងអស់ ដែលភាគីចាត់ទុកជាបុគ្គលសំខាន់ដើម្បីស្តាប់សក្ខីកម្ម បន្ថែមពីលើបុគ្គលទាំងឡាយដែលមានឈ្មោះក្នុងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី បណ្តោះអាសន្នរបស់អង្គជំនុំជម្រះដែលត្រូវស្តាប់សក្ខីកម្មនៅសវនាការ (ឯកសារ E131.1/1)។ ការសម្រេចជាស្ថាពរថាតើប្រសិនបើមាន សាក្សីណាខ្លះក្នុងចំណោមសាក្សីបន្ថែមទាំងនេះនឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មនៅសវនាការ ពុំមាននៅឡើយទេ និងកំពុងស្ថិតក្រោមការពិនិត្យរបស់អង្គជំនុំជម្រះ នៅពេលដែលសវនាការលើសំណុំរឿង ០០២/០១ មានដំណើរប្រព្រឹត្តទៅ។

00864724

E219/3

១៨. ជាចុងក្រោយ និងដូចដែលអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់នាពេលថ្មីៗនេះថា ដោយផ្អែកទៅលើសម្បថ ការសិក្សា និងបទពិសោធន៍នោះ ចៅក្រម "ត្រូវបានសន្មតថាមិនទទួលរងឥទ្ធិពលពីការផ្សព្វផ្សាយជាសាធារណៈ ដែលមានលក្ខណៈអវិជ្ជមាននោះទេ ជាពិសេសក្នុងករណីដែលមិនមានសញ្ញាណបង្ហាញពីឥទ្ធិពលបែបនេះ នៅក្នុងការវាយតម្លៃជារួមអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី"[31]។ ប៉ុន្តែសេចក្តីអត្ថាធិប្បាយ ពុំបានលើកឡើងអំពីបញ្ហាណាមួយដែលជា *កម្មវត្ថុនៃសវនាការនាពេលបច្ចុប្បន្ន* និងពុំបានសំដៅទៅដល់ជនជាប់ចោទ ឬទង្វើដែលត្រូវបានចោទប្រកាន់របស់គាត់ឡើយ។ បើទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តរបស់ខ្លួន អំពីការបំពេញកិច្ចការរដ្ឋបាលតុលាការប្រកប ដោយភាពត្រឹមត្រូវដែលធានាបានថា សេចក្តីអត្ថាធិប្បាយជាសាធារណៈរបស់មន្ត្រីនានាទាក់ទងនឹងការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០២ នឹងពុំមានឥទ្ធិពលមកលើអង្គជំនុំជម្រះ សាលាដំបូង ឬចៅក្រមណាម្នាក់របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឡើយ។ ថ្វីបើអង្គជំនុំជម្រះពុំមានមូលហេតុណាមួយអាចឱ្យជឿបានថា សេចក្តីអត្ថាធិប្បាយទាំងនេះបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ ឬមានបំណងជ្រៀតជ្រែកក៏ដោយ ក៏អង្គជំនុំជម្រះសូមបញ្ជាក់ថា វាមិនមានលក្ខណៈសមរម្យសម្រាប់មន្ត្រី សាធារណៈធ្វើសេចក្តីអធិប្បាយទាក់ទងនឹងការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅនោះឡើយ ហើយអង្គជំនុំជម្រះយល់ឃើញថា គួរមានការជៀសវាងនូវការធ្វើសេចក្តីអត្ថាធិប្បាយបែបនេះ ដែលអាចត្រូវបានគេយកមកបកស្រាយថា ធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ អ.វ.ត.ក[32]។

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បដិសេធ** សំណើរបស់មេធាវីការពារក្តី នួន ជា និងសេចក្តីបន្ថែមខ្លី ដោយផ្អែកលើអង្គសេចក្តីនៃឯកសារទាំងនេះ។

ភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២

**[illegible]ជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C • E T C

**និល ណុន**

៣១ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, [illegible]

៣២ សេចក្តីសម្រេចរបស់ អ.ជ.ត.កដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, កថាខណ្ឌ ៦៥-៦៦។